ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១១៥ សសរ. កសក

# សេចក្តីសម្រេច

## ស្តីពី

## ការបន្ថែមសមាសភាពក្រុមការងារផ្សព្វផ្សាយព័ត៌មាន តាមបណ្តាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកេ្សត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីណែនាំចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- បានឃើញសេចក្តីសម្រេចលេខ០១៧ សសរ.កសក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**ប្រការ ១._**

ត្រូវបានបន្ថែមភារកិច្ចជូនក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យធ្វើការតាមដាន ស្រង់ព័ត៌មានបណ្តាញសង្គម (ហ្វេសប៊ុក) របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលមានពាក់ព័ន្ធនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការឆ្លើយតប និងដោះស្រាយជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។

**ប្រការ ២._**

ក្រៅពីការបន្ថែមភារកិច្ចខាងលើ ខ្លឹមសារទាំងឡាយនៃសេចក្តីសម្រេចលេខ០១៧ សសរ.កសក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ត្រូវបានរក្សាទុកដដែល។

**ប្រការ ៣._**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ប្រធានអង្គភាពពាក់ព័ន្ធ និងក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងព័ត៌មាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០១៧ [illegible] កសក

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារផ្សព្វផ្សាយព័ត៌មាន តាមបណ្ដាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៀរក្រសាស្រ្តនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១ :** ត្រូវបានបង្កើតក្រុមការផ្សព្វផ្សាយព័ត៌មានតាមបណ្ដាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម **អ៊ឹង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

២. ឯកឧត្តម **ឡោ រស្មី** អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

៣.លោក **ហុង ណារិត** ប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម អនុប្រធាន

៤. ឯកឧត្តម **ឆេង គីមស៊ុន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ សមាជិក

៥. ឯកឧត្តម **អេង ជាសាន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល សមាជិក

៦. ឯកឧត្តម **សុខន ឫទ្ធីគុណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានកសិកម្ម សមាជិក

៧. ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានកៅស៊ូ សមាជិក

៨. លោក **តាន់ ផាន់ណារ៉ា** ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សមាជិក

៩. លោក **ស្រី ទុឡា** ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ សមាជិក

១០. លោក **ជា ចំន្ទរាសនា** អនុប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ប្រធានក្រុមលេខាធិការ

១១.លោក **កោ ម៉ិយរ័ន** ប្រធានការិយាល័យព័ត៌មានកសិកម្ម លេខាធិការ

១២.លោក **ឌីម រចនា** ប្រធានបណ្ណាល័យកសិកម្ម លេខាធិការ

១៣.លោក **សុខ សុគាធ** ប្រធានការិយាល័យព័ត៌មានភូមិសាស្ត្រកសិកម្ម លេខាធិការ

១៤. កញ្ញា **ទូច សុជាតា** មន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រី លេខាធិការ

**ប្រការ២ :** ក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានអំពីគោលនយោបាយ គោលការណ៍ និងសកម្មភាពសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនសាធារណជនទូទៅបានជ្រាបតាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក)
- បកស្រាយបំភ្លឺជូនសាធារណមតិឲ្យបានយល់ច្បាស់អំពីសភាពការណ៍វិវត្តន៍ និងបញ្ហាពាក់ព័ន្ធទៅនឹងសកម្មភាព ឬសេចក្តីសម្រេចនានារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក)
- ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារត្រូវធ្វើការទំនាក់ទំនងគ្នាជាប់ជាប្រចាំតាមរយៈបណ្តាញសង្គម ឬបណ្តាញទំនាក់ទំនងស្របតាមការកំណត់របស់ក្រុមការងារ
- សមាជិកក្រុមការងារដែលជាប្រធានអង្គភាពជំនាញនៃក្រសួង ត្រូវទទួលខុសត្រូវនិងធានាបញ្ជូនព័ត៌មាន មតិបកស្រាយបំភ្លឺលើមតិសាធារណជនពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួន មកក្រុមការងារឲ្យបានទាន់ពេលវេលាតាម រយៈបណ្តាញទំនាក់ទំនងរបស់ក្រុមការងារ ដើម្បីក្រុមលេខាធិការចាត់ចែងធ្វើសម្រង់ខ្លឹមសារ ផ្សព្វផ្សាយបំភ្លឺជូនសាធារណជនតាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក)
- ក្រុមការងារត្រូវប្រជុំប្រចាំខែ ឬនៅពេលវេលាចាំបាច់ណាមួយតាមការអញ្ជើញរបស់ប្រធានក្រុម ដើម្បីត្រួតពិនិត្យសកម្មភាពការងារ និងកំណត់ទិសដៅការងារដែលត្រូវអនុវត្តបន្ត។

**ប្រការ៣ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត វង្ស សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងព័ត៌មាន
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ